ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រដ្ឋបាលខេត្តកំពត
លេខៈ ០៨៩៤.១៦.សសរ

ក្រសួងមុខងារសាធារណៈ
រដ្ឋបាល
ចូល
លេខៈ ៤៥៦៧
មកដល់ថ្ងៃទី ០៨ ខែ ០៨ ឆ្នាំ ១៦
ម៉ោង ១០:៣០

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្តកំពត

## អភិបាល នៃគណៈអភិបាលខេត្តកំពត

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៧ ចុះថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលរាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣១៦/៣១៥ ចុះថ្ងៃទី ១៧ ខែ មីនា ឆ្នាំ ២០១៦ ត្រាស់បង្គាប់តែងតាំងអភិបាល នៃគណៈអភិបាលខេត្តកំពត
- បានឃើញអនុក្រឹត្យលេខ ២១៦ អនក្រ.បក ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០០៩ ស្តីពីតួនាទី ភារកិច្ច និងទំនាក់ទំនងការងាររបស់ក្រុមប្រឹក្សា គណៈអភិបាលខេត្ត ក្រុមប្រឹក្សា គណៈអភិបាលក្រុង និងក្រុមប្រឹក្សា គណៈអភិបាលស្រុក
- យោងប្រកាសលេខ ៤២៧៤ ប្រក ចុះថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០០៩ របស់ក្រសួងមហាផ្ទៃ ស្តីពីការបង្កើតការិយាល័យចំណុះទីចាត់ការនៃសាលាខេត្ត ការបង្កើតការិយាល័យនៃសាលាក្រុង ការបង្កើតការិយាល័យនៃសាលាស្រុក និងកំណត់តួនាទី ភារកិច្ច របៀបរបបការងារនៃការិយាល័យទាំងនោះ
- យោងលិខិតលេខ ១៨៤៦ មស.គករ ចុះថ្ងៃទី១៦ ខែមិថុនា ឆ្នាំ២០១៦ របស់ក្រសួងមុខងារសាធារណៈ
- ផ្អែកតាមការងារចាំបាច់របស់រដ្ឋបាលខេត្តកំពត ។

## *សម្រេច*

**ប្រការ១.-**

ត្រូវបានបង្កើតក្រុមការងារកែទម្រង់រដ្ឋបាលសាធារណៈខេត្តកំពត ដែលមានសមាសភាពដូចខាងក្រោម ៖

| | | | |
|---|---|---|---|
| ១- ឯកឧត្តម | **ចាន់ ចេស្តា** | អភិបាលខេត្ត | ប្រធាន |
| ២- ឯកឧត្តម | **ស៊ុក សារ៉ាដ** | អភិបាលរងខេត្ត | អនុប្រធាន |
| ៣- លោក | **ជិន វណ្ណថា** | ប្រធានមន្ទីរមុខងារសាធារណៈខេត្ត | អនុប្រធានអចិន្ត្រៃយ៍ |
| ៤-លោក | **ឡេង វិបុល** | នាយករងរដ្ឋបាលខេត្ត | សមាជិក |

| | | | |
|---|---|---|---|
| ៥-លោក | **ឃិន ប៊ុនអាន** | ប្រធានមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត | សមាជិក |
| ៦-លោក | **គង់ សំណាង** | ប្រធានរតនាគារខេត្ត | សមាជិក |
| ៧-លោក | **ណុប ចំនួដារិទ្ធ** | នាយកទីចាត់ការគ្រប់គ្រងធនធានមនុស្ស សាលាខេត្ត | សមាជិក |
| ៨-លោក | **ទិត ទឡ្ហនា** | នាយកទីចាត់ការអន្តរវិស័យ សាលាខេត្ត | សមាជិក |
| ៩-លោក | **ឡាយ សារឿន** | នាយកទីចាត់ការហិរញ្ញវត្ថុ សាលាខេត្ត | សមាជិក |
| ១០-លោកស្រី | **គង់ ប៊ុណ្ណារី** | នាយកទីចាត់ការផែនការ និងវិនិយោគ សាលាខេត្ត | សមាជិក |
| ១១-លោកអភិបាល នៃគណៈអភិបាលក្រុង ស្រុកគ្រប់ស្រុក | | | សមាជិក |
| ១២-លោក | **ខឹម សុផុន** | អនុប្រធានមន្ទីរមុខងារសាធារណៈខេត្ត | មន្ត្រីបង្គោល |
| ១៣-លោក | **ឃុត ពុទ្ធោ** | ប្រធានការិ.រដ្ឋបាល និងហិរញ្ញវត្ថុ នៃមន្ទីរមុខងារសាធារណៈខេត្ត | មន្ត្រីបង្គោល |

**ប្រការ២.-**

ក្រុមការងារនេះ មានតួនាទី ភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខប្រធានស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ក្នុងការគ្រប់គ្រងនិងដឹកនាំគ្រប់ការងារពាក់ព័ន្ធទៅនឹងកម្មវិធី យុទ្ធសាស្ត្រ និងសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈរបស់រដ្ឋបាលខេត្ត
- សម្របសម្រួលការងារកំណែទម្រង់រដ្ឋបាលសាធារណៈ រវាងរដ្ឋបាលខេត្តជាមួយនឹងលេខាធិការ-ដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- សម្របសម្រួល និងជំរុញការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងសកម្មភាពការងារកែទម្រង់រដ្ឋបាលសាធារណៈ
- រៀបចំផែនការសកម្មភាពកែទម្រង់រដ្ឋបាលសាធារណៈក្នុងដែនសមត្ថកិច្ចរបស់ខេត្ត
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ព្រមទាំងធ្វើរបាយការណ៍ ស្ដីពីវឌ្ឍនភាពនៃការអនុវត្តកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈជូនប្រធានស្ថាប័នសាមីជាប្រចាំ
- ត្រូវរាយការណ៍អំពីវឌ្ឍនភាពឲ្យបានទៀងទាត់រាល់ត្រីមាស ជូនលេខាធិការដ្ឋានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ ក្នុងការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ
- ត្រូវផ្ដល់កិច្ចសហការ និងសម្របសម្រួលជាមួយលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈតាមរយៈមន្ត្រីបង្គោល ក្នុងការស្វែងរក និងប្រមូលព័ត៌មានការរៀបចំផែនការសកម្មភាព ការអនុវត្ត ការតាមដានត្រួតពិនិត្យនិងវាយតម្លៃការរៀបចំរបាយការណ៍ និងបញ្ជូនរបាយការណ៍សង្ខេបនូវសូចនាករដែលទាក់ទងទៅនឹងវឌ្ឍនភាព នៃការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ឬនាយកដ្ឋានជំនាញនៃក្រសួងមុខងារសាធារណៈ ។ ជាពិសេស មន្ត្រីបង្គោល ត្រូវចូលរួមវគ្គបណ្ដុះបណ្ដាលស្ដីពីប្រព័ន្ធតាមដានត្រួតពិនិត្យ និងវាយតម្លៃសម្រាប់ការអនុវត្តកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ។

**ប្រការ៣.-**

ក្រុមការងារនេះ មានសិទ្ធិប្រើប្រាស់មន្ត្រីក្រោមឱវាទក្នុងករណីចាំបាច់សម្រាប់បំពេញតួនាទីភារកិច្ចឲ្យមានប្រសិទ្ធភាព ។

**ប្រការ៤.-**

បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយទៅនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍ ។

**ប្រការ៥.-**

រដ្ឋបាលខេត្តកំពត មន្ទីរ-អង្គភាពជុំវិញខេត្ត សាលាក្រុង ស្រុកគ្រប់ស្រុក និងសាមីខ្លួនដែលមានឈ្មោះក្នុងប្រការ១ ខាងលើ ត្រូវអនុវត្តសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

កំពត,ថ្ងៃទី២៨ ខែកក្កដា ឆ្នាំ ២០១៦

**អភិបាលខេត្ត**

**ចាន់ ចេស្តា**

***ចម្លងជូន***

- ក្រសួងមហាផ្ទៃ
- ក្រសួងមុខងារសាធារណៈ
  *"ដើម្បីជូនជ្រាប"*
- ដូចប្រការ៥
- ឯកសារ-កាលប្បវត្តិ